**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ០០៨/២៣ មស.ឥប ថ្ងៃអង្គារ ១២កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមករា ឆ្នាំ២០២៣

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន**

**កម្មវត្ថុ** ៖ ស្តីពីគោលការណ៍ប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងគ្រូបង្រៀនប្រភេទផ្សេងទៀត ជូនរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន សម្រាប់ឆ្នាំ២០២៣។

**យោង** ៖
- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលិខិតលេខ ២៥២២/២២ មស.ជម ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលិខិតលេខ ៥៨៥៧/២២ មស.ផក្រ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន** មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានយល់ព្រមផ្តល់ជាគោលការណ៍ជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន **៣,៨៦៣នាក់** មន្ត្រីជាប់កិច្ចសន្យាចំនួន **១៧,០២៤នាក់** មន្ត្រីថ្នាំទំនប់ប្រព័ន្ធជាសាស្ត្រជាប់កិច្ចសន្យាចំនួន **២៥០នាក់** គ្រូបង្រៀនពុទ្ធិកសិក្សាជាប់កិច្ចសន្យាចំនួន **១,៤៦២អង្គ/នាក់** គណៈគ្រប់គ្រងពុទ្ធិកសិក្សាចំនួន **៣៥២អង្គ/នាក់** គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅចំនួន **៩,៨៩៦នាក់** គ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរ-ឥស្លាមចំនួន **១៧៨នាក់** គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធចំនួន **២,៤៧២នាក់** គ្រូបង្រៀនពីរថ្នាក់ពីរពេល(២វេន)ចំនួន **១១,៦៧១នាក់** គ្រូបង្រៀនថ្នាក់គួបពីរចំនួន **២,៥៩៨នាក់** និងគ្រូបង្រៀនថ្នាក់គួបបីចំនួន **១២០នាក់** ដើម្បីផ្តល់ជូនរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន សម្រាប់ឆ្នាំ២០២៣ ដូចមានខាងក្រោម៖



ផ្លូវវិវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| ល.រ | ក្រសួង-ស្ថាប័ន | ក្របខ័ណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | | | គណៈគ្រប់គ្រងសាលាពុទ្ធិកសិក្សា | គ្រូបង្រៀនប្រភេទផ្សេងទៀត |
|---|---|---|---|---|---|---|---|
| | | | កិច្ចសន្យា | ឆ្មាំទំនប់ប្រព័ន្ធធារាសាស្ត្រ | គ្រូបង្រៀនពុទ្ធិកសិក្សា | | |
| ១ | ព្រះបរមរាជវាំង | ៦ | ២៥០ | | | | |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១៤ | ១១២ | | | | |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ៧ | ៥២ | | | | |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ៦ | ១៤៣ | | | | |
| ៥ | មហាផ្ទៃ | ២៦០ | ១,៥៣៨ | | | | |
| | ៥.១.មហាផ្ទៃ(គ.ជ.អ.ប) | | ១៦៨ | | | | |
| | ៥.២.មហាផ្ទៃ(ថែទាំកុមារតូចរបស់រដ្ឋ) | | ១១០ | | | | |
| | ៥.៣.សមាហរណកម្ម(ក្រុង ស្រុក ខណ្ឌ) | | ១២១ | | | | |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | ០ | ២៦០ | | | | |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ៨ | ១០០ | | | | |
| ៨ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៧៤ | ៥២០ | | | | |
| ៩ | ព័ត៌មាន | ២៤ | ៧១៥ | | | | |
| ១០ | សុខាភិបាល | ០ | ៣,០៥២ | | | | |
| ១១ | រ៉ែនិងថាមពល | ១១ | ២០០ | | | | |
| ១២ | ផែនការ | ២៧ | ១២៥ | | | | |
| ១៣ | ពាណិជ្ជកម្ម | ៦៥ | ២០៥ | | | | |
| ១៤ | អប់រំ យុវជន និងកីឡា | ៣០០០ | ៧០៤ | | | | |
| | ១៤.១.គ្រូបង្រៀនជាប់កិច្ចសន្យា | | | | | | ៩,៨៩៦ |
| | ១៤.២.គ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរ-ឥស្លាម | | | | | | ១៧៨ |
| | ១៤.៣.គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | | | | | | ២,៤៧២ |
| | ១៤.៤.គ្រូបង្រៀនពីរថ្នាក់ពីរពេល(២វេន) | | | | | | ១១,៦៧១ |
| | ១៤.៥.គ្រូបង្រៀនថ្នាក់គួបពីរ | | | | | | ២,៥៩៨ |
| | ១៤.៦.គ្រូបង្រៀនថ្នាក់គួបបី | | | | | | ១២០ |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៥២ | ៩៧៦ | | | | |
| ១៦ | វប្បធម៌និងវិចិត្រសិល្បៈ | ៦០ | ៧៩៧ | | | | |
| ១៧ | បរិស្ថាន | ៣១ | ៣៤៦ | | | | |
| ១៨ | អភិវឌ្ឍន៍ជនបទ | ៦ | ៨៧ | | | | |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | ១៣ | ៥៥៦ | | | | |
| ២០ | ប្រៃសណីយ៍និងទូរគមនាគមន៍ | ១៤ | ១២៦ | | | | |
| ២១ | ធម្មការនិងសាសនា | ៦ | ៥២៥ | | ១៤៦២ | ៣៥២ | |
| ២២ | កិច្ចការនារី | ៧ | ៣៩២ | | | | |
| ២៣ | សាធារណការនិងដឹកជញ្ជូន | ៦០ | ១,៥៤២ | | | | |
| ២៤ | យុត្តិធម៌ | | | | | | |
| | ២៤.១.ទីស្តីការក្រសួង | ៣ | ៦៨ | | | | |
| | ២៤.២.អគ្គនាយកដ្ឋានកិច្ចការតុលាការ | ០ | ៥៧៦ | | | | |

| ល.រ | ក្រសួង-ស្ថាប័ន | ក្របខ័ណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | | | គណៈគ្រប់គ្រងសាលាពុទ្ធិកសិក្សា | គ្រូបង្រៀនប្រភេទផ្សេងទៀត |
|---|---|---|---|---|---|---|---|
| | | | កិច្ចសន្យា | ឆ្មាំទំនប់ប្រព័ន្ធធារាសាស្ត្រ | គ្រូបង្រៀនពុទ្ធិកសិក្សា | | |
| ២៥ | ទេសចរណ៍ | ៩ | ៥៤៥ | | | | |
| ២៦ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១៦ | ៣១៨ | | | | |
| ២៧ | ធនធានទឹកនិងឧតុនិយម | ៤៤ | ៤៨១ | ២៥០ | | | |
| ២៨ | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២០ | ៣៩៧ | | | | |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ៣ | ២៨០ | | | | |
| ៣០ | មុខងារសាធារណៈ | ៦ | ៣៦៤ | | | | |
| ៣១ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១១ | ១៩៨ | | | | |
| ៣២ | គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | ០ | ៧៥ | | | | |
| **<u>សរុបរួម</u>** | | **៣,៨៦៣** | **១៧,០២៤** | **២៥០** | **១,៤៦២** | **៣៥២** | **២៦,៩៣៥** |

ក្នុងន័យនេះ ក្រសួងមុខងារសាធារណៈ សូមគោរពស្នើសុំរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន មេត្តាចូលរួមកិច្ចសហការអនុវត្តតាមគោលការណ៍ដែលបានកំណត់ដូចខាងក្រោម៖

**I. ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល**

១. បន្ទាប់ពីទទួលបានគោលការណ៍ជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន នីមួយៗ ត្រូវរៀបចំសំណើសុំប្រើប្រាស់ក្របខ័ណ្ឌ និងភ្ជាប់តារាងឧបសម្ព័ន្ធស្តីពីការបែងចែកប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល មកក្រសួងមុខងារសាធារណៈ យ៉ាងយូរត្រឹម២សប្តាហ៍ ដូចមានគោរពជូនភ្ជាប់តារាងឧបសម្ព័ន្ធគំរូ

២. ការជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ស្នើឱ្យរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ជាប្រធានគណៈកម្មការរៀបចំការប្រឡង ត្រូវសហការជាមួយតំណាងក្រសួងមុខងារសាធារណៈ ជាអនុប្រធាន ដើម្បីកំណត់បែបបទនីតិវិធីនៃការប្រឡងប្រជែងចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ប្រកាសលទ្ធផល

៣. រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ត្រូវរៀបចំការប្រឡងប្រជែងជ្រើសរើសក្នុងចំណោមសិស្ស-និស្សិត និងមន្ត្រីរាជការ ដោយធានាឱ្យមានតម្លាភាពនិងគណនេយ្យភាពខ្ពស់ផ្អែកលើគោលការណ៍គុណាធិបតេយ្យ ព្រមទាំងយកចិត្តទុកដាក់និងលើកទឹកចិត្តដល់បេក្ខភាពជាជនពិការភាពនិងជាស្ត្រី។ ដោយឡែកការប្រកាសលទ្ធផលប្រឡង ត្រូវរៀបចំផ្សព្វផ្សាយជាសាធារណៈយ៉ាងយូរត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៣ លើកលែងតែការប្រឡងប្រជែងជ្រើសរើសក្របខ័ណ្ឌរបស់ក្រសួងអប់រំ យុវជន និងកីឡា

៤. ករណីចាំបាច់ រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន អាចធ្វើសំណើសុំកិច្ចសហការមកក្រសួងមុខងារសាធារណៈ យ៉ាងយូរត្រឹមដំណាច់ខែមីនា ឆ្នាំ២០២៣ ដើម្បីរៀបចំការប្រឡងប្រជែងជំនួស

៥. ករណីចាំបាច់ដែលមានតម្រូវការធនធានមនុស្សរបស់រដ្ឋបន្ថែម រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ត្រូវរៀបចំសំណើមកក្រសួងមុខងារសាធារណៈ ដើម្បីមានលទ្ធភាពក្នុងការពិនិត្យ ពិភាក្សា និងលើកយោបល់គោរពស្នើសុំគោលការណ៍សម្រេច និងផ្តល់អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល។

**II. មន្ត្រីជាប់កិច្ចសន្យា មន្ត្រីឆ្មាំទំនប់ប្រព័ន្ធធារាសាស្ត្រជាប់កិច្ចសន្យា និងគ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា**

១. បន្ទាប់ពីទទួលបានគោលការណ៍ប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន នីមួយៗ ត្រូវរៀបចំសំណើសុំប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងភ្ជាប់តារាងឧបសម្ព័ន្ធស្តីពីការបែងចែកប្រើប្រាស់មន្ត្រី

ជាប់កិច្ចសន្យា មកក្រសួងមុខងារសាធារណៈ យ៉ាងយូរត្រឹម២សប្តាហ៍ ដើម្បីទទួលស្គាល់និងបញ្ចូលការបែងចែកការប្រើប្រាស់ជាក់ស្តែងទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដូចមានគោរពជូនភ្ជាប់តារាងឧបសម្ព័ន្ធគំរូ

២. រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ត្រូវធ្វើការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាតាមរយៈការប្រឡងប្រជែង (វិញ្ញាសាសរសេរ ឬសម្ភាសផ្ទាល់មាត់) ដោយត្រូវគោរពតាមគោលការណ៍និងលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងតិចមួយសប្តាហ៍ និងចម្លងជូនមកក្រសួងមុខងារសាធារណៈ
- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ ព្រមទាំងមានអាយុយ៉ាងតិច១៨ឆ្នាំ
- បេក្ខជនត្រូវបំពេញការងារសម្រាប់រយៈពេលយ៉ាងតិច ៣ខែ និងយ៉ាងច្រើន ១២ខែ ក្នុងឆ្នាំនីមួយៗ
- ពេលចូលបម្រើការងារត្រូវបំពេញប្រវត្តិរូបនិងបេបស្ម័យប្រកាស ដែលត្រូវបានធានាអះអាងនិងបញ្ជាក់ពីការប្រើប្រាស់ជាក់ស្តែងពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ឬនិងប្រធានអង្គភាពគ្រប់គ្រងផ្ទាល់

៣. រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ត្រូវរៀបចំប្រកាសបញ្ចូលការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាតាមតម្រូវការជាក់ស្តែងនៅក្នុងរចនាសម្ព័ន្ធរបស់សាមីក្រសួង-ស្ថាប័ន និងចម្លងជូនមកក្រសួងមុខងារសាធារណៈ

៤. ការបើកផ្តល់ប្រាក់កម្រៃមន្ត្រីជាប់កិច្ចសន្យា ត្រូវអនុវត្តតាមប្រព័ន្ធធនាគារ និងផ្អែកលើតារាងទូទាត់ប្រាក់កម្រៃប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងអាចរំលឹកប្រាក់កម្រៃចំនួន **០៣ខែ**(ខែមករា ដល់ ខែមីនា ឆ្នាំ២០២៣) និងអាចរំលឹកប្រាក់កម្រៃបានចំនួន **០១ខែ** សម្រាប់ការបើកផ្តល់ខែដំបូង ក្នុងករណីជ្រើសរើសថ្មី ឬជំនួសក្នុងលក្ខខណ្ឌរៀបចំសំណុំឯកសារយឺតយ៉ាវ

៥. ករណីមានបម្រែបម្រួលតួលេខមន្ត្រីជាប់កិច្ចសន្យាខុសពីតារាងឧបសម្ព័ន្ធស្តីពីការបែងចែកប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាដែលទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ ត្រូវស្នើសុំទិដ្ឋាការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ ដើម្បីធ្វើការផ្លាស់ប្តូរក្នុងប្រព័ន្ធព័ត៌មានវិទ្យា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន** មេត្តាជ្រាប និងមានចំណាត់ការដោយសេចក្តីអនុគ្រោះ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ៕

**រដ្ឋមន្ត្រី**

ព្រុំ សុខា

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

  " ដើម្បីជូនជ្រាប "
- នាយកដ្ឋានជ្រើសរើសមន្ត្រីរាជការនិងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍
- មន្ទីរមុខងារសាធារណៈ រាជធានី-ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្ត

  " ដើម្បីសហការអនុវត្ត "
- ឯកសារ-កាលប្បវត្តិ